**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៤៣៦ ... សហវ.ប្រក

ថ្ងៃ សុក្រ ១២ កើត ខែ បុស្ស ឆ្នាំ កុរ ឯកស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៩

# ប្រកាស

## ស្តីពី

## កម្មវិធីចំណូល-ចំណាយថវិកាថ្នាក់ជាតិប្រចាំត្រីមាសទី ២ ឆ្នាំ ២០១៩ របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ ព្រហស្បតិ៍ ០១រោច ខែ បឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៨/០១៧ ចុះថ្ងៃ ពុធ ០៥កើត ខែ មិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃ ពុធ ០៤រោច ខែ មិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៨ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩
- បានឃើញអនុក្រឹត្យលេខ ១៨៤ អនក្រ.បក ចុះថ្ងៃ ពុធ ០៤រោច ខែ មិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៨ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩
- ដោយមានការចាំបាច់ដើម្បីរក្សាតុល្យភាពនៃកិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ

## សម្រេច

**ប្រការ១:** ចំណូលរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមិនគិតនិងប្រមូលសម្រាប់ត្រីមាសទី ២ ឆ្នាំ ២០១៩ សរុបទឹកប្រាក់ ចំនួន ៦ ៤៦២ ៨០០ ០០០ រៀល (ប្រាំមួយប៊ីលានបួនរយហុកសិបពីរលានប្រាំបីរយពាន់រៀលគត់) ឬលើសកម្រិតកំណត់នេះ។ ចំណូលទាំងអស់នេះ ត្រូវបង់ចូលថវិកាថ្នាក់ជាតិឱ្យបានគ្រប់គ្រាន់និងទាន់ពេលវេលា ហើយត្រូវបានបែងចែកតាមជំពូកនៃមាតិកាថវិកានិងតាមខែដូចមានចែងក្នុងតារាងខាងក្រោមនេះ÷

ឯកតា:ពាន់រៀល

| ជំពូក | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៩ | កម្មវិធីចំណូលប្រចាំត្រីមាសទី២ | | | | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | សរុប | ខែមេសា | ខែឧសភា | ខែមិថុនា | |
| **សរុបរួម** | **27.564.800** | **6.462.800** | **2.154.300** | **2.154.300** | **2.154.200** | |
| ៧៣ | 27.444.800 | 6.429.200 | 2.143.100 | 2.143.100 | 2.143.000 | |
| ៧៤ | 120.000 | 33.600 | 11.200 | 11.200 | 11.200 | |

**ប្រការ២:** ចំនួនទឹកប្រាក់ជាអតិបរមា នៃឥណទានរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់ចំណាយប្រចាំត្រីមាសទី ២ ឆ្នាំ ២០១៩ ត្រូវបានកំណត់ស្មើនឹង ៤៧ ២២៨ ៨០០ ០០០ រៀល (សែសិបប្រាំពីរប៊ីលានពីររយម្ភៃប្រាំបីលានប្រាំបីរយពាន់រៀលគត់)។ ចំនួនទឹកប្រាក់នៃឥណទាននេះ ត្រូវបានបែងចែកតាមជំពូកនៃមាតិកាថវិកានិងតាមខែដូចមានចែងក្នុងតារាងខាងក្រោមនេះ÷

ឯកតា:ពាន់រៀល

| ជំពូក | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៩ | កម្មវិធីចំណាយប្រចាំត្រីមាសទី២ | | | | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | សរុប | ខែមេសា | ខែឧសភា | ខែមិថុនា | |
| **សរុបរួម** | **167.329.600** | **47.228.800** | **11.716.030** | **17.982.685** | **17.530.085** | |
| ៦០ | 29.800.600 | 9.023.630 | 1.794.910 | 2.958.310 | 4.270.410 | |
| ៦១ | 27.381.000 | 9.846.535 | 1.908.945 | 2.129.645 | 5.807.945 | |
| ៦៤ | 62.671.400 | 18.521.768 | 5.110.786 | 8.190.741 | 5.220.241 | |
| ៦២ | 33.121.400 | 7.565.907 | 2.034.869 | 3.910.569 | 1.620.469 | |
| ៦៥ | 14.295.200 | 2.270.960 | 866.520 | 793.420 | 611.020 | |
| ៦៣ | 60.000 | 0 | 0 | 0 | 0 | |

**ប្រការ៣:** អាណត្តិបើកប្រាក់ ដែលចេញដោយអាណាប័កដើមខ្សែលើសពីចំនួនទឹកប្រាក់កម្រិតកំណត់ខាងលើ និងលើសពីការបែងចែកតាមជំពូកនៃថវិកាខាងលើ មិនត្រូវបានទទួលការចុះទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទេ ហើយក៏មិនត្រូវបានធ្វើការបើកផ្តល់ដោយបេឡាគនាគារដែរ។

**ប្រការ៤:** រាល់ចំណាយចាំបាច់លើសពីកម្រិតកំណត់ឥណទានដូចមានចែងក្នុងប្រការ២ ត្រូវមានការអនុញ្ញាតពីឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៥:** អាណាប័កដើមខ្សែក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**ចម្លងជូន**

- អគ្គនាយកដ្ឋានរតនាគារជាតិ
- នាយកដ្ឋានហិរញ្ញកិច្ច
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ